DSHS WASHINGTON STATE Department of Social and Health Services

សិទ្ធិ និងទំនួលខុសត្រូវលើ ជំនួយសាច់ប្រាក់ និង ម្ហូបអាហាររបស់អ្នក

Your Cash and Food Assistance Rights and Responsibilities

ឈ្មោះអតិថិជន (មេគ្រួសារ)
លេខ ID អតិថិជន

ទំនួលខុសត្រូវរបស់អ្នក (អ្នកត្រូវតែ)

- ផ្តល់មកយើងនូវព័ត៌មានដែលយើងត្រូវការដើម្បីចិត្តថាតើអ្នកមានសិទ្ធិទទួលបានដែរឬទេ។
- ផ្តល់មកយើងនូវភស្តុតាង នៅពេលគេត្រូវការវា។ យើងប្រហែលជាអាចទទួលវាសម្រាប់អ្នក។
  ព័ត៌មានដែលអ្នកផ្តល់មកកាន់ក្រសួងគឺអាចប្រែប្រួលតាមការផ្សេងផ្តាត់ដោយមន្ត្រីសហព័ន្ធ និងមន្ត្រីរដ្ឋ។
  ការផ្សេងផ្តាត់អាចអាចរួមបញ្ចូលនូវការទាក់ទងតាមដានពីបុគ្គលិកក្រសួងដែលរួមទាំងអ្នកស៊ើបអង្កេតលើការក្លែងបន្លំ។
- ព័ត៌មានដែលបានរាយការណ៍ទៅក្រសួងសេវាសង្គម និងសុខភាព អាចជះឥទ្ធិពលទៅលើភាពមានសិទ្ធិទទួលបានការធានារ៉ាប់រង
  ថែទាំសុខភាពដែលបានគ្រប់គ្រងដោយអាជ្ញាធរថែទាំសុខភាព និងការផ្លាស់ប្តូរអត្ថប្រយោជន៍សុខភាព។
- ការផ្លាស់ប្តូរបាយការណ៍ (ឧទា. អាសយដ្ឋាន ប្រាក់ចំណូល ជាដើម។) ដូចដែលបានតម្រូវនៅក្នុង WAC 388-418-0005។
  រាយការណ៍ពួកវាត្រឹមថ្ងៃទី 10 នៃខែបន្ទាប់។
- សហការជាមួយផ្នែកជំនួយការ **(DCS)** ប្រសិនបើអ្នកទទួលយកការផ្តល់ជូន TANF។ អ្នកត្រូវតែជួយ DCS បង្កើត កែប្រែ
  ឬដាក់ឱ្យអនុវត្តជំនួយកុមារសម្រាប់កូន(ៗ)នៅក្នុងការថែទាំរបស់អ្នក និងបង្កើតភាគរយ (បើចាំបាច់) ដូចដែលបានតម្រូវនៅក្នុង WAC
  388-422-0005។ អ្នកអាចបដិសេធសហការជាមួយ DCS ប្រសិនបើអ្នកអាចបង្ហាញថាអ្នកមាន
  ហេតុផលល្អដែលជឿថាការសហការជាមួយ ដាក់អ្នក កូនៗរបស់អ្នក ឬក្មេងៗនៅក្នុងការថែទាំរបស់អ្នកស្ថិតក្នុងហានិភ័យនៃគ្រោះថ្នាក់ពី
  ឪពុកម្តាយមិនមើលថែទាំ។
- ដាក់ពាក្យសុំ និងធ្វើកិច្ចប្រឹងប្រែងសមហេតុផលដើម្បីទទួលប្រាក់ចំណូលគួរឱ្យកត់សម្គាល់ពីប្រភពផ្សេងទៀត នៅពេលអ្នកស្នើសុំ
  ឬទទួលបានជំនួយសាច់ប្រាក់។
- បំពេញរបាយការណ៍ និងការពិនិត្យមើលដែលបានតម្រូវ។
- អនុវត្តតាមតម្រូវការការងារ សម្រាប់ជំនួយសាច់ប្រាក់ និងជំនួយម្ហូបអាហារ។
- ប្រាប់យើងថាតើអ្នកចង់ឱ្យនរណាម្នាក់ផ្សេងទៀតប្រើប្រាក់ជំនួយម្ហូបអាហាររបស់អ្នកក្នុងនាមអ្នកឬអត់។
- សហការជាមួយអ្នកពិនិត្យមើលការគ្រប់គ្រងគុណភាពរបស់យើង។
- ប្រើជំនួយម្ហូបអាហារ តែដើម្បីទិញម្ហូបអាហារសម្រាប់សមាជិកនៃគ្រួសាររបស់អ្នកប៉ុណ្ណោះ។
- ប្រើជំនួយសាច់ប្រាក់ តែសម្រាប់អត្ថប្រយោជន៍នៃសមាជិកគ្រួសាររបស់អ្នកប៉ុណ្ណោះ។
- អ្នកត្រូវតែផ្តល់លេខសន្តិសុខសង្គម (SSN) ឬស្ថានភាពអន្តោប្រវេសន៍ តែសម្រាប់មនុស្សដែលដាក់ពាក្យសុំជំនួយប៉ុណ្ណោះ។
  ប្រសិនបើអ្នកជ្រើសរើសមិនផ្តល់ SSNs ឬស្ថានភាពអន្តោប្រវេសន៍សម្រាប់សមាជិកគ្រួសារដែលមិនដាក់ពាក្យទេ ប្រាក់ចំណូល
  និងធនធានរបស់សមជិកគ្រួសារទាំងអស់ត្រូវតែត្រូវផ្សេងផ្តាត់ដដែល បើត្រូវការ ដើម្បីកំណត់ពីភាពមានសិទ្ធិទទួល។

សិទ្ធិរបស់អ្នក (អ្នកត្រូវតែ)

- ទទួលយកពាក្យសុំដែលមានឈ្មោះ អាសយដ្ឋាន និងហត្ថលេខារបស់អ្នក ឬហត្ថលេខារបស់តំណាងដែលមានសិទ្ធិអនុញ្ញាតរបស់អ្នក។
- ជួយអ្នកបំពេញទម្រង់បែបបទ **DSHS** ។
- ដំណើរការសំណើរបស់អ្នកសុំជំនួយម្ហូបអាហារក្នុងពេលប្រាំពីរ (7) ថ្ងៃ ប្រសិនបើអ្នកមានលក្ខណសម្បត្តិសម្រាប់សេវាកម្មរហ័ស។
- ផ្តល់ឱ្យអ្នកនូវបង្កាន់ដៃ ប្រសិនបើអ្នកស្នើសុំមួយ នៅពេលអ្នកផ្តល់ឯកសារ។
- ផ្តល់ឱ្យអ្នកនូវការសម្រេចចិត្តជាលាយលក្ខណ៍ ក្នុងករណីភាគច្រើន ក្នុងពេល 30 ថ្ងៃ។
- អ្នកអាចបដិសេធមិននិយាយទៅអ្នកអ្នកស៊ើបអង្កេត ការរកឃើញមុនពេលអំពីការក្លែងបន្លំ (FRED) ពីការិយាល័យការក្លែងបន្លំ
  និងគណនេយ្យភាព។ អ្នកមិនចាំបាច់ឱ្យអ្នកស៊ើបអង្កេតចូលទៅក្នុងផ្ទះរបស់អ្នកនោះទេ។ អ្នកអាចស្នើឱ្យស៊ើបអង្កេតត្រលប់មកវិញ
  នៅពេលផ្សេង។ នេះនឹងមិនជះឥទ្ធិពលលើភាពមានសិទ្ធិទទួលបានជំនួយរបស់អ្នកនោះទេ។

សិទ្ធិរបស់អ្នក (អ្នកត្រូវតែ) បន្ត

- អ្នកអាចស្នើសុំសវនាការរដ្ឋបាល ប្រសិនបើអ្នកមិនយល់ស្របតាមសេចក្តីសម្រេចដែលក្រសួងធ្វើនៅលើករណីរបស់ខ្ញុំ។ អ្នកក៏អាចស្នើអ្នកត្រួតពិនិត្យ ឬអ្នកគ្រប់គ្រងពិនិត្យមើលសេចក្តីសម្រេច ឬសកម្មភាពដែលមានជម្លោះផងដែរ ដោយមិនជះឥទ្ធិពលលើសិទ្ធិរបស់អ្នកចំពោះសវនាការរដ្ឋបាលនោះទេ។
- យើងត្រូវតែជូនដំណឹងទៅអ្នកអំពីវិធានដែនកំណត់ពេលវេលា 60 ថ្ងៃ ក្រោមកម្មវិធី ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារដែលខ្វះខាត (TANF)។ ការកំណត់ពេលវេលាមិនអនុវត្តទៅម្ហូបអាហារមូលដ្ឋានរបស់អ្នក ឬឧបត្ថម្ភធនថែទាំកុមារនោះទេ។

រឿងរ៉ាវដែលអ្នកគួរដឹងអំពីកាត **EBT** របស់អ្នក

- ការប្រើប្រាស់ខុសនៃអត្ថប្រយោជន៍៖ អត្ថប្រយោជន៍ម្ហូបអាហារ និងសាច់ប្រាក់ដែលបានចែករំលែកតាមរយៈកាត EBT នឹងផ្តល់ឱ្យ DSHS នូវប្រវត្តិប្រតិបត្តិការ ដែលអ្នកបានប្រើអត្ថប្រយោជន៍របស់អ្នក។ ក្រសួងនឹងប្រើប្រាស់ព័ត៌មានអំពីប្រតិបត្តិការក្នុងការស៊ើបអង្កេតពីការប្រើខុសនូវអត្ថប្រយោជន៍ជំនួយសាច់ប្រាក់ ឬការផ្លាស់ប្តូរនូវអត្ថប្រយោជន៍ជំនួយម្ហូបអាហារសម្រាប់សាច់ប្រាក់ ឬធាតុផ្សេងទៀតនៃតម្លៃ (ការជួញដូរ)។
- ការប្តូរកាត **EBT** ថ្មី៖ យើងអាចគិតថ្លៃសម្រាប់ការប្តូរកាត EBT ថ្មី។ រក្សាកាត EBT របស់អ្នក និងលេខអត្តសញ្ញាណផ្ទាល់ខ្លួន (PIN) របស់អ្នកឱ្យមានសុវត្ថិភាព និងសន្តិសុខ។
- កាត **EBT** ដែលមានសមតុល្យខ្ពស់៖ ប្រសិនបើអ្នកមិនប្រើអត្ថប្រយោជន៍របស់អ្នករយៈពេលជាច្រើនខែក្នុងមួយពេល ឬបង្ករទុកសមតុល្យខ្ពស់បន្ទាប់ពីពេលបីបួនខែ យើងអាចទាក់ទងទៅអ្នកដើម្បីពិនិត្យមើលស្ថានភាពរបស់អ្នក ឬសេចក្តីត្រូវការសម្រាប់អត្ថប្រយោជន៍របស់អ្នក។

រឿងរ៉ាវដែលអ្នកគួរដឹង (ម្ហូបអាហារមូលដ្ឋាន)

- យើងពិតជាផ្ញើព័ត៌មានអំពីបុគ្គលម្នាក់ៗដែលដាក់ពាក្យសុំ ម្ហូបអាហារមូលដ្ឋាន ទៅឱ្យបណ្តាទីភ្នាក់ងារសហព័ន្ធ ដើម្បីពិនិត្យមើលថាតើព័ត៌មាននេះត្រឹមត្រូវឬអត់។ ប្រសិនបើព័ត៌មានណាមួយមិនត្រឹមត្រូវ នោះបុគ្គលដែលដាក់ពាក្យអាចនឹងមិនទទួលបាន ម្ហូបអាហារមូលដ្ឋាននោះទេ។ ប្រសិនបើបុគ្គលម្នាក់ផ្តល់ព័ត៌មានដែលពួកគេដឹងថាវាមិនត្រឹមត្រូវ ពួកគេអាចជាប់ទោសព្រហ្មទណ្ឌ។ ការផាកពិន័យសម្រាប់ការបំពានវិធាន ម្ហូបអាហារមូលដ្ឋាន ដោយចេតនា ខុសគ្នាពីការលុបចោលលក្ខណៈសម្បត្តិ ពីកម្មវិធី ដែលត្រូវផាកពិន័យ ឬអាចជាប់ពន្ធនាគារ។
- ប្រសិនបើអ្នកលក់ ប៉ុនប៉ងលក់ ផ្លាស់ប្តូរ ឬឧបត្ថម្ភជំនួយម្ហូបអាហាររបស់អ្នក សម្រាប់អ្វីមួយដែលមានតម្លៃ ដូចជា សាច់ប្រាក់ ឱសថ អាវុធ ឬអ្វីមួយក្រៅពីម្ហូបអាហារពីអ្នកលក់រាយដែលមានសិទ្ធិ (ការជួញដូរ) អ្នកអាចត្រូវបានលុបចោលលក្ខណៈសម្បត្តិពីការទទួលបានអត្ថប្រយោជន៍ជំនួយម្ហូបអាហារសម្រាប់រយៈពេលអប្បបរមាមួយឆ្នាំរហូតដល់ការបាត់លក្ខណៈសម្បត្តិពេញមួយជីវិតជាអតិបរមានៅលើបទល្មើសលើកដំបូងនេះ។ ការបាត់លក្ខណៈសម្បត្តិនេះបន្ត សូម្បីតែអ្នកចាកចេញពីរដ្ឋ Washington ហើយដាក់ពាក្យសុំអត្ថប្រយោជន៍នៅក្នុងរដ្ឋផ្សេង។
- ប្រសិនបើអ្នកត្រូវបានតម្រូវឱ្យចូលរួមក្នុងតម្រូវការការងារម្ហូបអាហារមូលដ្ឋាន ហើយបរាជ័យមិនបានចូលរួម អ្នកអាចត្រូវបានលុបចោលលក្ខណសម្បត្តិរយៈពេលមួយខែ ហើយរហូតទាល់តែអ្នកព្រមធ្វើតាមតម្រូវការការងារសម្រាប់បរាជ័យលើកដំបូង; រយៈពេលបីខែ ហើយរហូតទាល់តែអ្នកអនុវត្តសម្រាប់បរាជ័យជាលើកទីពីរ; និងរយៈពេលប្រាំមួយខែ ហើយរហូតទាល់តែអ្នកអនុវត្តសម្រាប់លើកទីបី និងរាល់ពេលទីមួយៗបន្ទាប់ពីពេលនោះមក។
- អ្នកប្រហែលជាត្រូវដកចេញពីកម្មវិធីម្ហូបអាហារមូលដ្ឋាន សម្រាប់ការបំពានវិធានកម្មវិធីម្ហូបអាហារមូលដ្ឋាន ដូចដែលបានរៀបរាប់នៅក្នុងការព្រមានផាកពិន័យម្ហូបអាហារមូលដ្ឋានដែលមានរាយនៅលើទំព័រនេះ។
- រាយការណ៍ពីការចំណាយរបស់គ្រួសារ ប្រសិនបើអ្នកចង់ឱ្យក្រសួងរួមបញ្ចូលថ្លៃចំណាយទាំងនេះសម្រាប់ម្ហូបអាហារមូលដ្ឋាន។ ប្រសិនបើអ្នកមិនរាយការណ៍ ហើយផ្តល់នូវភស្តុតាងនៃការចំណាយទាំងនេះ នោះអ្នកកំពុងតែថ្លែងថាអ្នកមិនចង់ឱ្យយើងប្រើប្រាស់ការចំណាយទាំងនេះដើម្បីសម្រេចចិត្តថាតើអ្នកអាចទទួលបានម្ហូបអាហារមូលដ្ឋានបន្ថែមទៀតនោះទេ។

រឿងរ៉ាវដែលអ្នកគួរតែដឹង (សាច់ប្រាក់ - **TANF**)

ដោយការទទួលជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារដែលខ្វះខាត **(TANF)** អ្នកចាត់ចែងសិទ្ធិគាំទ្រកូន និងប្តី ឬប្រពន្ធរបស់អ្នកទៅឱ្យផ្នែកជំនួយកុមារ។ នេះមានន័យថា DCS អាចរក្សាជំនួយវិញ (ប្រាក់ដែលដល់ថ្ងៃត្រូវបង់) ដែលដល់ពេលត្រូវសង ខណៈពេលអ្នកទទួលបាន TANF។ DCS នឹងផ្ញើទៅអ្នកនូវជំនួយបច្ចុប្បន្នដែលបានប្រមូលខណៈពេលដែលអ្នកទទួលបាន TANF។

- អ្នកត្រូវតែប្រាប់ **DCS** ភ្លាម។ ប្រសិនបើអ្នកបានទទួលការបង់ប្រាក់ជំនួយកុមារ និងអត្ថប្រយោជន៍ផ្សេងៗ សម្រាប់កុមារខណៈពេលនៅលើ TANF។
- ប្រសិនបើអ្នកឈប់ទទួល **TANF** អ្នកត្រូវតែប្រាប់ DCS អំពីការផ្លាស់ប្តូរទាំងឡាយដែលប៉ះពាល់ដល់ជំនួយកុមារ ដូចជាថាតើកុមារលែងរស់នៅជាមួយអ្នកឬយ៉ាងណា ឬអាសយដ្ឋានរបស់អ្នកប្រែប្រួល។
- ប្រសិនបើអ្នកទទួល **TANF** អ្នកអាចស្នើសុំលុយបន្ថែម ដើម្បីជួយបង់សម្រាប់ថ្លៃលំនៅដ្ឋានគ្រាមានអាសន្នបណ្តោះអាសន្ន។

រឿងរ៉ាវដែលអ្នកគួរតែដឹង (សាច់ប្រាក់ - **RCA**)

ដោយការទទួលជំនួយសាច់ប្រាក់សម្រាប់ជនភៀសខ្លួន **Refugee Cash Assistance, RCA)**៖

- អ្នកត្រូវតែនៅលីវ ឬជាបុគ្គលដែលរៀបការរួចតែមិនទាន់មានកូននៅក្នុងគ្រួសារ។ អ្នកត្រូវតែប្រាប់យើង ប្រសិនបើអ្នកប្រែជាមានផ្ទៃពោះ ឬត្រូវតែថែទាំកូន ដោយសារតែអ្នកអាចមានសិទ្ធិទទួលបានកម្មវិធីអត្ថប្រយោជន៍សាច់ប្រាក់មួយផ្សេង។
- អ្នកមានសិទ្ធិទទួលបានរហូតដល់ទៅដប់ពីរ **(12)** ខែនៃជំនួយសាច់ប្រាក់សម្រាប់ជនភៀសខ្លួន ផ្អែកលើស្ថានភាពអន្តោប្រវេសន៍របស់អ្នក និងកាលបរិច្ឆេទដែលអ្នកបានក្លាយជាមានសិទ្ធិទទួលបានកម្មវិធី និងសេវាកម្មជនភៀសខ្លួនសហព័ន្ធ។
- អ្នកត្រូវតែចូលរួមក្នុងសេវាការងារ និងការបណ្តុះបណ្តាល ក្នុងពេល 30 ថ្ងៃនៃការទទួលបានជំនួយ ដែលអាចរួមទាំងសកម្មភាពនានាដើម្បីជួយអ្នកទទួលបានការងារធ្វើ ឬរៀនភាសាអង់គ្លេស។ អ្នកប្រហែលមិនអាចត្រូវតែចូលរួមក្នុងសេវាកម្មទាំងនេះនោះទេ ប្រសិនបើអ្នកមានពិការភាពធ្ងន់ធ្ងរ ឬរ៉ាំរ៉ៃ ត្រូវតែនៅផ្ទះដើម្បីថែទាំមនុស្សពេញវ័យម្នាក់ទៀតដែលមានពិការភាព មានអាយុ 60 ឆ្នាំឡើងទៅ ឬជាជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ។
- ជាផ្នែកនៃតម្រូវការការងារ និងសេវាបណ្តុះបណ្តាល អ្នកត្រូវតែចូលរួមការសម្ភាសការងារទាំងអស់ ទទួលយកការផ្តល់ជូនការងារសមហេតុផល (លុះត្រាតែវាទីងផ្តុយពីកិច្ចព្រមព្រៀងសហជីពដែលអ្នកជាសមាជិក ឬការងារគឺទំនេរដោយសារជម្លោះពលករ) ហើយប្រហែលមិនអាចលាឈប់ពីការងារដោយគ្មានហេតុផលល្អមួយ ដូចដែលបានសម្រេចដោយយើងឡើយ។
- អ្នកមានសិទ្ធសម្រាប់ការងារសមស្រប និងសេវាផ្តល់ការងារ និងការបណ្តុះបណ្តាល។ ការងារ និងសេវាផ្តល់ការងារ និងការបណ្តុះបណ្តាលទាំងអស់ត្រូវតែមានសុវត្ថិភាព មិនរើសអើង រួមបញ្ចូលទាំងសកម្មភាពនានាដែលស្ថិតនៅក្នុងវិសាលភាពនៃផែនការសេវាការងារ / ការរៀបរំជាបុគ្គលរបស់អ្នក និងដែលអ្នកអាចអនុវត្តនៅលើមូលដ្ឋានទៀតទាត់ ពាក់ព័ន្ធចំនួនម៉ោងដែលជាធម្មតាសម្រាប់ការងារ និងស្ថិតនៅក្នុងពេលវេលាទៅមកកន្លែងធ្វើការសមហេតុផល (មិនយូរជាងពីរម៉ោង ឬអ្វីដែលវាសមហេតុផលសម្រាប់តំបន់នោះ)។ សេវាបណ្តុះបណ្តាលត្រូវតែទំនងជានាំទៅរកអ្នកឱ្យទទួលការងារមួយ ហើយប្រាក់ឈ្នួលត្រូវតែបំពេញបាន ឬលើសពីប្រាក់ឈ្នួលអប្បបរមា ឬត្រូវតែមិនតិចយ៉ាងគួរឱ្យកត់សម្គាល់ជាងអ្វីដែលជាធម្មតាត្រូវបានបង់សម្រាប់ការងារស្រដៀងគ្នា។
- ប្រសិនបើអ្នកត្រូវបានតម្រូវឱ្យទទួលយកការផ្តល់ជូនការងារ ឬចូលរួមក្នុងសេវាការងារ និងការបណ្តុះបណ្តាល **RCA** ហើយបរាជ័យមិនបានធ្វើដូច្នេះ ជំនួយរបស់អ្នកនឹងត្រូវបានបញ្ឈប់ ឬកាត់បន្ថយ។ ការកាត់បន្ថយមានរយៈពេលបីខែសម្រាប់ការមិនចូលរួមលើកដំបូង និងប្រាំមួយខែសម្រាប់ការមិនចូលរួមទីមួយៗបន្ទាប់ពីនោះមក។
- អ្នកត្រូវតែរាយការណ៍មកយើងនូវប្រាក់ចំណូលទាំងឡាយ ប្រសិនបើអ្នកទទួលបានការងារត្រឹមថ្ងៃទី 10 នៃខែបន្ទាប់។
- ប្រសិនបើអ្នកជាជនពិការ ពិការភ្នែក ឬមានអាយុលើសពី **65** ឆ្នាំ អ្នកអាចទទួលបាន RCA ខណៈពេលដែលអ្នកដាក់ពាក្យសុំកម្មវិធីជំនួយផ្សេងទៀតជាមួយ រដ្ឋបាលសន្តិសុខសង្គម (Social Security Administration, SSA)។ យើងនឹងជួយអ្នកដាក់ពាក្យសុំកម្មវិធីទាំងនោះ។ នៅពេលអ្នកត្រូវបានអនុម័តសម្រាប់កម្មវិធីជំនួយជាមួយ RCA នោះអត្ថប្រយោជន៍ RCA របស់អ្នកនឹងឈប់។
- អ្នកមិនអាចទទួល **RCA** នោះទេ ប្រសិនបើ ក្នុងពេល ៣០ថ្ងៃ មុនពេលពាក្យសុំរបស់អ្នក អ្នកលាឈប់ពីការងាររបស់អ្នក ឬបានបដិសេធការផ្តល់ជូនការងារសមហេតុផលមួយដោយគ្មានហេតុផលល្អមួយ។

សេចក្តីថ្លែងពីសិទ្ធិស៊ីវិល និងការមិនរើសអើង

ដោយយោងតាមច្បាប់សិទ្ធិស៊ីវិលសហព័ន្ធ និងបញ្ញត្តិ និងគោលនយោបាយសិទ្ធិស៊ីវិល USDA, USDA, ទីភ្នាក់ងាររបស់ខ្លួន ការិយាល័យ បុគ្គលិក និងស្ថាប័ននានាដែលចូលរួមក្នុង USDA ឬដែលគ្រប់គ្រងកម្មវិធី គឺត្រូវបានហាមឃាត់ពីការរើសអើងផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ប្រភពដើមជាតិសាសន៍ សាសនា ភេទ ពិការភាព អាយុ ស្ថានភាពអាពាហ៍ពិពាហ៍ ស្ថានភាពគ្រួសារ / ឪពុកម្តាយ ប្រាក់ចំណូលដែលបានមកពីកម្មវិធីជំនួយសាធារណៈ ជំនឿនយោបាយ ឬការផ្តាំញ៉ាតប ឬការសងសឹកសម្រាប់សកម្មវិធីសិទ្ធិស៊ីវិលមុនហ្នឹង នៅក្នុងកម្មវិធី ឬសកម្មភាពទាំងឡាយដែលដឹកនាំ ឬផ្តល់មូលនិធិដោយ USDA (មិនមែនគ្រប់មូលដ្ឋានទាំងអស់អនុវត្តសម្រាប់គ្រប់កម្មវិធីនោះទេ)។ ការដោះស្រាយ និងកាលបរិច្ឆេទដាក់បណ្តឹងខុសគ្នាតាមកម្មវិធី ឬត្រាតំថ្នាក់។

បុគ្គលដែលមានពិការភាពដែលតម្រូវឱ្យមានមធ្យោបាយផ្សេងនៃការប្រាស្រ័យទាក់ទងសម្រាប់ព័ត៌មានកម្មវិធី (ឧទា អក្សរស្មាប អក្សរពុម្ពធំ ការសែតអូឌីយ៉ូ ភាសាសញ្ញាអាមេរិក ជាដើម។) គួរតែទាក់ទងទីភ្នាក់ងាររដ្ឋ ឬក្នុងមូលដ្ឋានដែលគ្រប់គ្រងកម្មវិធី ឬទាក់ទង USDA តាមរយៈ សេវាបញ្ជូនបន្តទូរគមនាគមន៍ (Telecommunications Relay Service) តាមលេខ 711 (សំឡេង និង TTY)។ លើសពីនេះ ព័ត៌មានកម្មវិធីអាចធ្វើឱ្យរកបានជាភាសាផ្សេងៗក្រៅពីភាសាអង់គ្លេស។

ដើម្បីដាក់បណ្តឹងការរើសអើងកម្មវិធី ចូរបំពេញទម្រង់បែបបទបណ្តឹងការរើសអើងកម្មវិធី USDA, AD-3027, ដែលរកឃើញលើអនឡាញនៅ របៀបដាក់បណ្តឹងការរើសអើងកម្មវិធី និងនៅការិយាល័យ USDA ទាំងឡាយ ឬសរសេរលិខិតមួយដែលមានចុះអាសយដ្ឋានទៅកាន់ USDA និងផ្តល់នៅក្នុងលិខិតនោះនូវព័ត៌មានទាំងអស់ដែលបានស្នើសុំនៅក្នុងទម្រង់បែបបទនេះ។ ដើម្បីស្នើសុំច្បាប់ចម្លងមួយនៃទម្រង់បែបបទបណ្តឹង ហៅទៅលេខ (866) 632-9992។ ដាក់ស្នើទម្រង់បែបបទ ឬលិខិតដែលបំពេញរួចរបស់អ្នកទៅកាន់ USDA តាម៖

1. សំបុត្រ៖ USDA Food and Nutrition Service, 1320 Braddock Place, Room 334 Alexandria, VA 22314; ឬ
2. អ៊ីមែល៖ FNSCIVILRIGHTSCOMPLAINTS@usda.gov។

ស្ថាប័ននេះគឺជាអ្នកផ្តល់ឱកាសស្មើភាពគ្នា។

ដោយការចុះហត្ថលេខាខាងក្រោម ខ្ញុំកំពុងតែថ្លែងថា ខ្ញុំមានសិទ្ធិ និងទំនួលខុសត្រូវរបស់ខ្ញុំលើការទទួលបានអត្ថប្រយោជន៍ និងកម្មវិធី DSHS ដែលបានពន្យល់មកកាន់ខ្ញុំ។ ខ្ញុំយល់ប្រសិនបើខ្ញុំបដិសេធចុះហត្ថលេខាលើឯកសារនេះ វាមិនប៉ះពាល់ដល់សិទ្ធិទទួលរបស់ខ្ញុំនោះទេ ប៉ុន្តែខ្ញុំនៅរក្សាទំនួលខុសត្រូវសម្រាប់តម្រូវការកម្មវិធី និងទទួលរងតាមការពិន័យកម្មវិធី ឬបទឧក្រិដ្ឋានាដែលអនុវត្ត។

ហត្ថលេខារបស់អ្នកដាក់ពាក្យ	កាលបរិច្ឆេទ	ហត្ថលេខារបស់សហអ្នកដាក់ពាក្យ	កាលបរិច្ឆេទ

ACES ID បុគ្គលិក DSHS ៖ ☐ បានបដិសេធចុះហត្ថលេខា។